**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ០៤ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីកំណត់អត្តសញ្ញាណពលករកម្ពុជា ដែលកំពុងធ្វើការខុសច្បាប់នៅព្រះរាជាណាចក្រថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការនៃការប្រើប្រាស់កម្លាំងពលកម្ម
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសហការជាមួយស្ថានឯកអគ្គរាជទូតកម្ពុជានៅព្រះរាជាណាចក្រថៃ និងក្រុមការងារអន្តរក្រសួងចល័តតាមគោលដៅ ដើម្បីកំណត់អត្តសញ្ញាណពលករកម្ពុជា ដែលកំពុងធ្វើការ ខុសច្បាប់នៅព្រះរាជាណាចក្រថៃ ដូចមានសមាសភាពខាងក្រោម :

ក- ក្រុមការងារអន្តរក្រសួងដើម្បីសហការជាមួយស្ថានឯកអគ្គរាជទូតកម្ពុជានៅព្រះរាជាណាចក្រថៃ :

| | | |
|---|---|---|
| ១- លោក **សេង សក្ដា** | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- តំណាងស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅព្រះរាជាណាចក្រថៃ | | អនុប្រធាន |

www.pheakdeylaw.com

៣- លោក **ចន ចណ្ណា**: អនុប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៤- លោក **ឆី សេរីវឌ្ឍ** នាយកខុទ្ទកាល័យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៥- លោក **ជួរ អៀងលី** អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៦- លោក **ញៀម គឹមហួយ** ប្រធានការិយាល័យរកការងារឱ្យធ្វើ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

ខ- ក្រុមការងារអន្តរក្រសួងចល័តតាមគោលដៅ :

**ក្រុមទី ១ :**

១- លោកវរសេនីយ៍ទោ **ឆន ឆុន្ថា** នាយកការិយាល័យនាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ប្រធាន

២- លោក **ម៉ី ចន្ទវិសាល** អនុប្រធានការិយាល័យគ្រប់គ្រងជនបរទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៣- លោក **តែ ពៅ** មន្ត្រីនាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ក្រុមទី ២ :**

១- លោកអនុសេនីយ៍ទោ **ហាក់ សិរីរណៈ** មន្ត្រីនាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ប្រធាន

២- លោក **ម៉ី ឆុន្ធី** មន្ត្រីការិយាល័យត្រួតពិនិត្យកម្មករនិយោជិតខ្មែរ អនុប្រធា

៣- លោក **ម៉ម ច័ន្ទតិរក្ស** មន្ត្រីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា សមាជិក

**ក្រុមទី ៣ :**

១- លោក **ឃឹម សុគន្ធ** មន្ត្រីនាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ប្រធាន

២- លោក **ឃឹម ផល្លី** អនុប្រធានការិយាល័យទំនាក់ទំនង នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធ

៣- លោក **ផូ ឧស្សាហ៍រចនា** មន្ត្រីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា សមាជិ

www.pheakdeylaw.com

**ក្រុមទី ៤ :**

១- លោកព្រឹទ្ធបាលឯក **ហុង ដារ៉ា** មន្ត្រីនាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ប្រធាន

២- លោក **ស៊ូ ផល្លា** មន្ត្រីការិយាល័យរកការងារឱ្យធ្វើ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៣- លោក **មុំ ទាសនា** មន្ត្រីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុក កិច្ចការអភិវឌ្ឍបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា សមាជិក

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

ក- ក្រុមការងារអន្តរក្រសួង ដើម្បីសហការជាមួយស្ថានឯកអគ្គរាជទូតកម្ពុជានៅព្រះរាជាណាចក្រថៃ :

- គ្រប់គ្រងរាល់ការងារទាំងឡាយ ដែលក្រុមការងារទាំងបួនបញ្ជូនមក
- ពិនិត្យ និងសម្រេចចេញនូវលិខិតសម្គាល់ខ្លួន Certificate of Identity (C.I) ជូនពលករ
- ធ្វើសំណើមកក្រសួងមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីស្រាវជ្រាវបន្តចំពោះពលករ ដែលពុំមានឯកសារ និងអត្តសញ្ញាណច្បាស់លាស់ ។

ខ- ក្រុមការងារអន្តរក្រសួងចល័តតាមគោលដៅ :

- ធ្វើសម្ភាសន៍ និងផ្ទៀងផ្ទាត់ឯកសារពលករ ដើម្បីធ្វើសេចក្តីសន្និដ្ឋាន និងស្នើសុំការកំណត់អត្តសញ្ញាណពលករបញ្ជូនមកក្រុមការងារប្រចាំនៅស្ថានឯកអគ្គរាជទូតកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ សប្តាហ៍ និងខែ ជូនក្រុមការងារប្រចាំការនៅស្ថានឯកអគ្គរាជទូតកម្ពុជា។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com